# វគ្គ មិត្តបន្ទប់ជួល

«វណ្ណ! ក្មួយវណ្ណ!»

នាងផ្ទៀងត្រចៀកស្ដាប់ ពីព្រោះមិនចំណាំបានថា នរណាម្នាក់ឈ្មោះវណ្ណទេ។ ទើបតែរើមកនៅទីនេះបានប្រហែលជាប្រាំពីរឬប្រាំបីថ្ងៃ ហើយភាគច្រើនអត់ដែលបាននៅបន្ទប់ពេលថ្ងៃទាល់តែសោះរវល់ច្រើនរហូតដល់យប់ទើបចូលមកគេងតែម្ដង។

ធម្មតាម្ដុំនេះស្ងាត់ណាស់ សុទ្ធតែជាបន្ទប់ជួលនៅក្បែរមហាវិទ្យាល័យផង ប៉ុន្តែជាប្រភេទបន្ទប់តូចៗច្រើនជាន់ឡើងចុះខ្ពស់ សក្ដិសមសម្រាប់តែយុវវ័យ និស្សិតៗដែលស្នាក់តែឯងម្ចាស់ផ្ទះមិនអនុញ្ញាតឱ្យពពាក់ពពូនឡើយសូម្បីកូនក្មេងម្នាក់ក៏មិនងាយបានឃើញដែរ។

ម្នាក់ៗនៅក្បែរៗនេះ មានការងាររវល់ព្រលឹមបាត់ព្រលប់ចូល។

«វណ្ណបានសន្យាថា ឱ្យថ្លៃឈ្នួលផ្ទះមីងនៅតាំងពីម្សិល ប៉ុន្តែអត់ឃើញដល់ឥឡូវ?»

ពេលផ្ទៀងត្រចៀកស្ដាប់ ស្គាល់ម្ចាស់សំឡេងនេះជាមីងម៉ាប់ម្ចាស់ផ្ទះជួល។

«គេមិនទាន់បើកលុយឱ្យណាមីង គេសន្យាថាថ្ងៃចន្ទណាមីងបានជាមិនទាន់មាន!»

«ថ្ងៃចន្ទ? បីថ្ងៃទៀតឯណោះ! ក្មួយនិយាយកុហកឬមួយក៏យ៉ាងម៉េច អាណិតមនុស្សចាស់ណា! កុំឱ្យពិបាកឡើងចុះមកសួរនាំច្រើនដង!»

«ខ្ញុំសន្យា! ត្រឹមថ្ងៃចន្ទណាមីង មិនចាំបាច់មីងឡើងមកទៀតទេ! ក៏សូមអរគុណដែលមីងតែងយោគយល់!»

នាងតឹងទ្រូងហើយងាកទៅរៀបចំកន្លែងគេង។

នៅពេលជូតសម្អាតព្រមព្យាណូសំណព្វចិត្ត ចិត្តស្រីនៅភ្នកគិតទៅដល់រឿងដែលទើបនឹងឮមកពីបន្ទប់ជាប់ខាង។ ជីវិតជាអ្នកជួលផ្ទះគេ មករស់នៅកសាងអាជីពតែលតោលនៅក្រុងភ្នំពេញធម្មតាវាកម្សត់រួចទៅហើយ រឿងដែលរឹតតែកម្សត់ទៅទៀត គឺបើសិនជាមិនមានថ្លៃឈ្នួលផ្ទះឱ្យគេ ហើយត្រូវគេឱ្យរើចុះចេញ តើអារម្មណ៍បែបនោះអ្នកណាយល់? មានតែអ្នកដែលមានប្រវត្តិជួលបន្ទប់ដូចគ្នាទើបដឹង! ខ្លះក្នុងរយៈពេលពីរឆ្នាំ ត្រូវរើកន្លែងរហូតដល់ទៅប្រាំឬប្រាំមួយដង ដោយសារតែក្ដីសង្ឃឹមថានឹងរកបានការងារធ្វើ ឬក៏រកបានដែរប៉ុន្តែមិនជាប់លាប់។

តរុណីជ្រុះបំភ្លេចចោលបណ្ដារឿងទុក្ខព្រួយ នៅពេលដែលងាកមកក្រឡេកឃើញសំណុំឯកសារពីបងពិស្ដា។

សេចក្ដីសង្ឃឹម គឺជាវត្ថុតែមួយគត់ដែលជាចំណែកនៃចំណុចខ្លាំងនៅក្នុងជីវិតរបស់នារីនេះ ពេលដែលនាងបានសម្រេចចិត្តចាកចេញ ខេត្តកំពង់ចាមមកកាន់ភ្នំពេញ។ ស្រីបានតាំងចិត្តថា ប្រសិនបើមិនទាន់មានលទ្ធផលណាមួយ ដែលជាសេចក្ដីថ្លៃថ្នូរ បង្កើតនូវការគោរពចំពោះឪពុកម្ដាយក្រុមគ្រួសារវង្សត្រកូលខ្លួនឯង ក៏នឹងមិនចុះចាញ់ មិនចាកចេញពីទីក្រុងគជ់ដាច់ខាត គឺតស៊ូរហូតដល់ចុងបញ្ចប់។

សំឡេងច្រៀងមួយយ៉ាងក្រអួនក្រអៅ លាន់ឮមកដល់ត្រចៀកកវី។ ការស្ដាប់ឮមនុស្សឡូឡាច្រៀងខារ៉ាអូខេជារឿងរំខានសឹងក្លាយជាធម្មតាទៅហើយនៅក្នុងរាជធានីដ៏ចង្អៀតនេះ ប៉ុន្តែសំនៀងគ្មានភ្លេងនេះ បានផ្ញើមកដល់បេះដូងរបស់នាងនូវអនុស្សាវរីយ៍កាលពីព្រឹក។

ព្រឹកមិញនាងពិតជាបានឮវាម្ដងរួចមកហើយ។

បទដដែលនេះដែរ ឥឡូវលាន់ចេញមកពីអ្នកដែលនៅជាប់បន្ទប់នេះ ឈ្មោះវណ្ណម្នាក់នោះហើយ ដែលទើបនឹងមានទុក្ខសោករឿងថ្លៃបន្ទប់ជួល។

គេនេះជាម្នាក់ប្រុសចូលប្រលងចម្រៀងនៅG-Brothers ព្រឹកមិញឬក៏មិនមែន?

កវីស្រីទម្លាក់កន្សែងជូតដីចោល ឈានដើរមកក្បែរបង្អួចភ្នែករំពៃសម្លឹងទៅខាងឆ្វេងដៃ ដែលជាប្រភពនៃសំឡេង។ ច្រៀងពិតណាស់គេនៅទីនោះ ព្រោះឃើញកំភួនដៃនេះក៏ចំណាំបានទោះបីជាគេមិនបានពាក់អាវដូចកាលពីព្រឹក ឬមួយក៏ប្រហែលជាពាក់អាវវាល។

ភពផែនដីនេះចង្អៀតពេកហើយទីបំផុតយើងគឺជាអ្នកជួលផ្ទះជិតគ្នា។

នារីនេះមិនបានបង្អាក់គេឱ្យឈប់ច្រៀងនោះទេ ព្រោះថាគេស្រាប់តែឈប់ច្រៀងខ្លួនឯង ហើយនៅសង្រ្គួមធ្វើមុខស្រងូតសម្លឹងចុះទៅផ្លូវខាងក្រោមដែលស្ងាត់ច្រៀបក្រោមតំណក់ភ្លៀងស្រិចៗរលោងស្រិល។

ភាពស្ងប់ស្ងាត់នេះ ជាឱកាសឱ្យនាងប្រើពាក្យ«សួស្ដី»ទៅកាន់គេ។

«សួស្ដី!»

នេះគឺជាទម្លាប់របស់នាងនៅពេលនិយាយទៅកាន់អ្នកណាម្នាក់ដែលទើបជួបគ្នាជាលើកដំបូងប៉ុន្តែព្រឹកមិញយើងជួបគ្នារួចហើយគ្រាន់តែជាធ្វើកាយវិការគដាក់គ្នា។

សំឡេងរបស់នារីជាប់ខាង បានទាញអារម្មណ៍គេឱ្យងាកមកស្ដាប់ គេក៏ហាក់ភ្ញាក់ផ្អើលនៅពេលដែលឃើញនាង ម្ល៉ោះហើយស្រីញញឹមស្ងួតទៅកាន់គេ។

គេញញឹមមកវិញស្វាគមន៍នាងតែគ្មានវាចាអ្វីបន្ថែមពីលើស្នាមញញឹមនោះទៀតទេ។ បុរសនេះ អាចថាហាក់កំពុងអៀនដែលគេគិតថានាងឮគេច្រៀងម្នាក់ឯងអម្បាញ់មិញ ម្ល៉ោះហើយគេលើកដៃជ្រោងសក់ឱ្យរៀបរយឡើងបន្តិច បណ្ដាលឱ្យស្រីឃើញអាវយឺតដៃវាលរបស់គេជាមួយរាងកាយដ៏ធំមាំសង្ហាសក្ដិសម។

«ខ្លួនហ្មែនដែលលេងព្យាណូពេលល្ងាចម្សិលម៉ិ្ញ?» ខាងប្រុសចាប់ផ្ដើមចរចាដោយប្រយោគសំណួរ។

នារីវេភ្នែកគិតរកនឹកចុះឡើងភ្លាមៗថា តើខ្លួនបានលេងបទអីខ្លះមួយរយៈមុននេះ? លេងទាំងមិនដឹងថាមានម្នាក់ ជាអ្នកស្នេហាសិល្បៈដូចគ្នាកំពុងស្នាក់នៅក្បែរនេះនិងបានលបស្ដាប់វា។

ទីបំផុតមាណវីងក់ក្បាលតិចៗទាំងញញឹមទទួលថា ជានាងពិតមែន។ នេះជាចរិតរបស់អង្គលក្ខិណានៅពេលដែលប្រទះជាមួយមនុស្សប្រុសស្អាតសង្ហា ស្រឡាញ់វ័យនិងមាននិស្ស័យសិល្បៈដូចគ្នា ក៏ក្លាយជាមិនសូវមានពាក្យនិយាយអ្វីច្រើន បានត្រឹមញញឹមយោង។ ណាមួយគេនេះ មិនត្រឹមមានសព្ទសំឡេងក្រអួនក្រអៅដែលនាងលបស្ងើចសរសើរតាំងពីព្រឹកមិញ ពេលនេះទៀតសោតកំពុងតែសន្ទនាគ្នា នាងបានប្រទះឃើញរូបរាងខ្ពស់សង្ហារបស់គេច្បាស់ឡើងៗរហូតលេចចេញអៀនប្រៀនជាសម្ងាត់ឱ្យគ្នាទៅវិញទៅមក។

គេទម្លាក់ទឹកមុខស្ងួតប្រហែលជានឹកឃើញដល់ការសន្ទនាជាមួយមីងម៉ាប់អ្នកជួលផ្ទះបាញ់មិញ ហើយគិតថានាងឮ។ ទឹកមុខបុរសនេះបានបង្ហាញចេញមកនូវស្ថានភាពតឹងតែងដែលគេកំពុងប្រឈមមុខ ហើយអ្វីដែលស្រីអាចធ្វើបានគ្មានអ្វីក្រៅពីការលើកទឹកចិត្តគេដោយនិយាយឡើងថា៖

«ខ្ញុំគិតថា ការប្រលងព្រឹកមិញ នឹងបានលទ្ធផលល្អ! ខ្ញុំឈ្មោះលក្ខិណា! ហៅខ្ញុំអង្គក៏បាន ឈ្មោះនៅផ្ទះរបស់ខ្ញុំ!»

«លក្ខិណាគិតចឹងដែរ? ខ្ញុំឈ្មោះវណ្ណ ឈ្មោះដើមថាសុវណ្ណ តែក្នុងសិល្បៈខ្ញុំដាក់ឈ្មោះខ្លួនឯងថា សក្កាវណ្ណ!»

«រីករាយណាស់ដែលបានស្គាល់!»

«រីករាយដូចគ្នា! នែ យល់ថាបទចម្រៀងខ្ញុំព្រឹកមិញច្រៀងស្ងួតគ្មានភ្លេងអ៊ីចឹងម៉េចដែរ?!»

«ច្រៀងបានល្អណាស់! ប៉ុន្តែ....»

«ប៉ុន្តែយ៉ាងម៉េចទៅ?»

គេហាក់ដូចជាទម្លាក់ទឹកមុខ ដូចជាមានសេចក្ដីអស់សង្ឃឹមខ្លះលេចឡើង ដូច្នេះអង្គព្យាយាមបំពេញចន្លោះនេះឱ្យគេ គឺវាចាបន្ត៖

«អឺ គឺថា បើសិនជាមានឱកាសនោះ វណ្ណគួរតែមានបទចម្រៀង Original មួយសម្រាប់ខ្លួនឯងជាជាងច្រៀងបទអ្នកចម្រៀងផ្សេង ដែលមិនមែនបង្កើតមកសម្រាប់ត្រូវនឹងToneចម្រៀង ឬបុគ្គលិកលក្ខណៈរបស់យើង!»

គូសន្ទនាដូចជាយល់ស្របជាមួយយោបល់នាងតាមរយៈកាយវិការទ្រឹងស្ដាប់ដោយពិចារណាស្ងប់ស្ងាត់។ មិនយូរប៉ុន្មានគេតបមកវិញ៖

«ខ្ញុំគិតថា អង្គយល់ពីតន្ត្រីច្រើន! តែនិយាយពិតទៅ ខ្ញុំមិនចេះធ្វើមេឡូឌី ឬសរសេរទំនុកច្រៀងអីទេ!»

«អ៊ីចឹង រកជំនួយទៅ! រកខ្ញុំជួយធ្វើឱ្យបានតាស៎!»

«ខ្ញុំអត់មានលុយទេ!»

«ខ្ញុំនឹងយកលុយ ប៉ុន្តែពេលក្រោយ! បានអត់? ពេលវណ្ណជោគជ័យចាំឱ្យក៏បាន! ខ្ញុំជួយសរសេរ Lyricឱ្យ ហើយខ្ញុំនឹងរកភ្លេងមួយដែលសក្តិសមជាមួយនឹងទឹកមុខ ព្រមជាមួយសំឡេងរបស់វណ្ណ!»

បុរសញញឹមដោយអំណរសម្លឹងនាង តែក៏រុះរោយទៅវិញភ្លាមៗជំនួសដោយវាចាថ្មី៖

«ល្អដែរ អរគុណណាស់! តែចាំខាង G-Brother គេហៅយើង ទៅលើកទីពីរសិនចាំគិតទៀត!»

«មិនមែនទេ! ត្រូវត្រៀមឱ្យហើយវណ្ណ! ត្រូវថ្មីកនិងមានពេលគ្រប់គ្រាន់ហ្វឹកហាត់វាផង! អ៊ីចេះទៅ! ខ្ញុំនឹងរៀបចំថាសរសេរពេលណាឱ្យ នឹងឆាប់បានយកទៅហាត់សម!»

បុរសស្រាប់តែផ្លោះភ្លែតចេញពីបង្អួចនាយមកឈរក្បែរនាងនៅរបៀងខាងក្រៅបន្ទប់ដែលគ្មានទេបង្កាន់ដៃ។ សកម្មភាពនេះធ្វើឱ្យអង្គបើកភ្នែកធំៗនិងលើកដៃខ្ទប់មាត់ពីព្រោះដំបូងឡើយនាងភ័យ តែឃើញគេហាក់មិនអីជាមួយទឹកមុខមានទំនុកចិត្តខ្ពស់ ក្រោយមកនាងញញឹមហាក់ហួសចិត្តវិញ។ យល់ចិត្តខាងស្រី វណ្ណស្រដី៖

«ខ្ញុំរំភើបពេក!»

គេនិយាយខ្លីៗ ជាមួយសព្ទសំឡេងស្រទន់ពីធម្មជាតិ ដែលគេមានមកយ៉ាងពិសេស។ អារម្មណ៍រិជ្ជមានរវាងមនុស្សពីរនាក់ ជាធម្មតាជួបប្រទះក្នុងវ័យយុវភាពដែលគួបផ្សំរវាងនិស្ស័យត្រូវគ្នា និយាយស្ដីគាប់ចិត្តគ្នា ភាពស្និទ្ធស្នាល ទុកចិត្ត កក់ក្ដៅដែលផ្ដល់នូវបង្អួចដ៏គួរឱ្យចាប់អារម្មណ៍មួយដល់គ្នាទៅវិញទៅមកគឺជាបាតុភូតធម្មជាតិនៃមនុស្ស។

«ហេតុអីចង់ជួយខ្ញុំ អ្ហះ?»

បុរសសួរមកទៀត ធ្វើឱ្យនារីវេភ្នែកចុះឡើងរកនឹកពាក្យឆ្លើយ។ នាងជួយអ្នកផង ទុកជារឿងធម្មតាទៅហើយក្នុងជីវិតនេះ តែលើកនេះដោយសារអ្វី? នាងក៏ឆ្លើយមិនបានខ្លួនឯងដែរ។

បេះដូងនេះឆាប់ចុះចាញ់សំឡេងពីរោះៗដែលកម្ររកបាននោះទេដឹង?

មនុស្សស្អាតសង្ហានៅក្បែរបង្អើយ កាន់តែធ្វើឱ្យនាងមានសម្ពាធថ្មី ប៉ុន្តែនៅពេលដែលក្រឡេកឃើញឯកសាររបស់បងពិស្ដា អង្គនឹកឃើញថាមានហេតុផលឆ្លើយហើយ។

«ខ្ញុំមានពេលតែពីរសប្ដាហ៍ទៀតទេ នៅក្នុងការបញ្ចប់គម្រោងការសាកល្បងមួយជូនលោកពិស្ដាដែលជាផលិតករល្បីនៅ G-Brothers! ព្រឹកមិញខ្ញុំទៅហ្នឹងដើម្បីជួបគាត់! តើអាចទេគិតបែបនេះទៅ គិតថាខ្ញុំរកបានសំឡេងពិសេសមួយអ្នកផងមិនដែលបានឮ ដើម្បីបង្កើតទំនុកភ្លេងថ្មីមួយ ផ្ដោតតាមបែបបទនៃសំឡេងរបស់វណ្ណ ឱ្យមានលក្ខណៈថ្មីសន្លាង!»

គេនៅភ្លឹកសម្លឹងនាង អង្គវាចាបន្ថែម៖

«បានន័យថាយើងជួយគ្នាទៅវិញទៅមក!»

«អស្ចារ្យណាស់!»

គេភ្លាត់មាត់តិចៗ មុនពេលនិយាយមកទៀតបន្ថែម៖

«លោកពិស្ដានោះល្បីខ្លាំងណាស់! អង្គមានឱកាសបានជួបគាត់បានន័យថា អង្គក៏ជាមនុស្សមានទេពកោសល្យខ្ពស់ស្រាប់ទៅហើយ! មិនដឹងថាខ្ញុំមានសមត្ថភាពចាប់យកឱកាសនេះឬអត់?»

អង្គញញឹមខ្ចីបនៅពេលឮគេហៅនាងថា«មានទេពកោសល្យខ្ពស់»។ ស្នាមញញឹមរបស់នាង ធ្វើឱ្យវណ្ណនឹកឃើញទៅដល់ពាក្យមួយថា«បានក្លាយជាហេតុផលដែលនរណាម្នាក់ញញឹមនៅថ្ងៃនេះ ជាជោគជ័យនៃទំនាក់ទំនងក្នុងជីវិតមិនថាអាជីពឬរឿងផ្ទាល់ខ្លួនទេ»។

ជាយូរមកហើយគេស្ទើរតែបានភ្លេចផងថា គេបាត់ភាពញញឹមទៅណាអស់អំពីជីវិត? ឆាកយុវវ័យមួយដែលចង់ធ្វើតាមបេះដូងចំណង់ចំណូលចិត្ត កសាងអាជីពក្នុងវិថីសិល្បៈ ផ្លាស់ទីលំនៅមកឆ្ងាយពីផ្ទះ ជារឿងដ៏គួរឱ្យរំភើបពីដំបូង ប៉ុន្តែក៏គួរឱ្យភ័យខ្លាចផងដែរ នៅពេលដែលបានប្រឈមនឹងបរាជ័យ ឯកោ គ្មានបណ្ដាញនិង«គ្មានអ្វីទាំងអស់»សូម្បីប្រាក់សងថ្លៃបន្ទប់ជួលឱ្យបានទៀងទាត់។ នារីនេះជាទិព្វនិម្មិតលោកិយទម្លាក់ឱ្យមកលើកទឹកចិត្តមនុស្សឯកោគ្មានអ្វីទាំងអស់ដូចយើង?

គេហាក់ដូចជាមានកែវភ្នែកស្រទន់ឡើងៗនៅពេលដែលឃើញស្នាមញញឹមរបស់នាង។ ជាបណ្ដើរៗ វណ្ណចាប់ផ្ដើមលួចក្រឡេកសង្កេតមើលសម្រស់របស់អង្គ។

អារម្មណ៍ជាមនុស្ស ស្រីអង្គអាចដឹងបានថាបុរសនេះកំពុងតែលបលួចពិនិត្យនាងតែគេសម្លឹងតែបន្តិចប៉ុណ្ណោះក៏តតាំងនឹងបេះដូងជម្លៀសភ្នែកចេញទៅវិញ។

អង្គដឹងបានថាវណ្ណអាចមានការអៀនប្រៀន។ ពិតណាស់ ស្ថានភាពរបស់គេក្នុងពេលនេះ ឋានៈរបស់គេ ហោប៉ៅទទេរបស់គេ គឺប្រាកដណាស់ វណ្ណមិនបានត្រៀមខ្លួនរួចរាល់នៅក្នុងការមានសង្សារ ឬក៏ញ៉ែស្រីនោះទេ។

ទោះបីយ៉ាងណាអង្គដូចគ្នា។ ស្រីក៏មិនបានគិតពីរឿងស្នេហាឬចំណងមនោសញ្ចេតនាអ្វីឡើយ។ នាងគ្រាន់តែស្ដាយមនុស្សមានទេពកោសល្យម្នាក់ដែល កំពុងសឹងបាត់កន្លែងជ្រកផង។ នាងពោលបន្ថែមលើកទឹកចិត្តនាយ៖

«កុំទាន់បាត់ទំនុកចិត្តតែក៏កុំសង្ឃឹមខ្ពស់លើខ្ញុំពេក! ចាំមើលសិនថា តើយើងអាចធ្វើអីបានសម្រាប់រឿងនេះ!»

«រឿងអី?» ខាងប្រុសងាកមកសួរវិញភ្លាម។ នាងង៉េមង៉ាម មិនដឹងថាមួយស្រង្វូតនេះ គេគិតទៅដល់អ្វីខ្លះទេ បានជាបែរមកសួរវិញខ្លីៗនិងមិនសូវជាទំនង។

អង្គឆ្លើយ៖

«គឺរឿងការងារចម្រៀងនេះ! ខ្ញុំចង់សរសេរទំនុកមួយ គឺរឿងសរសេរភ្លេងថ្មីមួយ ត្រូវជាមួយនឹងសំឡេងរបស់សក្កាវណ្ណវិញ! បើសិនជាព្រហ្មលិខិតបណ្ដាលឱ្យខ្ញុំគិតឃើញអ្វីមួយនៅក្នុងរយៈពេលនេះខ្ញុំអាចនឹងសរសេរណោតភ្លេងឡើង ហើយបន្តទៅLyricទៀត! ចង់និយាយថាសិល្បៈគឺជានិស្ស័យ វាមិនអាចបង្ខំបានទេ! ដូចជាការងារខ្ញុំជាមួយផលិតករពិស្ដាគឺស្ដែងចេញពីឱកាស ២សប្ដាហ៍នេះ! ប្រសិនបើខ្ញុំរកមិនបានចំនួនបទតាមគាត់តម្រូវ ឬយ៉ាងហោចណាស់បានបីបទបានន័យថាខ្ញុំក៏អត់មានមុខត្រឡប់ទៅជួបគេវិញដូចគ្នា! ចំណែកបទភ្លេងហើយនិងទំនុកច្រៀងគឺយើងមិនអាចបង្ខំបានទេ ប្រសិនបង្ខំ យករបស់ដែលមិនចេញពីបេះដូងរបស់យើងហើយវាមិនពីរោះពិសាដូចដែលយើងចង់បានយកទៅដាក់ឱ្យគេពិនិត្យ គឺស្មើនឹងធ្វើឱ្យគេលែងទុកឱកាសក្រោយៗឱ្យយើងទៀតក៏ថាបាន!»

ចាប់ពីថ្ងៃនោះហើយដែលនាងក៏ដឹងថា គេមានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យប៉ុន្តែសំនៀងរបស់គេមិនមានរដឹនត្រង់ណាសូម្បីតែបន្តិច ធ្វើឱ្យអង្គពិបាកសម្គាល់ដឹងថាគេជាអ្នកមកពីពាយព្យ។

គេអាចច្រៀងនូវបទចម្រៀងពីដើមនិងសម័យបានច្រើនប្រភេទថែមទាំងមាន

ទេពកោសល្យ អ៊ីន កន្លុកគន្លាក់ក្នុងលក្ខណៈពិសេសខុសពីអ្នកចម្រៀងមុនៗផង។

ទោះបីយ៉ាងណា នៅក្រោយស្គាល់គ្នាជជែកបានច្រើនដងនាងហ៊ានសួរពីវិធីរកចំណូលផ្គត់ផ្គង់ជីវភាពរបស់គេ ពេលនោះហើយនាងបានដឹងទៀតថា ដោយសារសេចក្ដីបំណងចង់ក្លាយជាអ្នកចម្រៀងអាជីពដែលជាគោលដៅធំមកភ្នំពេញនេះ ធ្វើឱ្យគ្រួសារគេអន់ចិត្តជាខ្លាំង។

ពុកគេដែលខឹងថា គេមិនព្រមបន្តការសិក្សានៅមហាវិទ្យាល័យបែរជាទៅធ្វើការក្នុងហាង

ភីហ្សាមួយដើម្បីយកលុយមកផ្គត់ផ្គង់ការហូបចុកស្នាក់នៅនិងបន្តសមបទចម្រៀងស្វែងរកឱកាសនៅក្នុងការប្រលងច្រៀងមិនជាប់ជាច្រើនលើក បានផ្អាកមិនព្រមនិយាយរកឬមកសួរសុខទុក្ខគេជាច្រើនខែមកហើយ។

«ហេតុអីបានជាវណ្ណ មិនទៅច្រៀងនៅតាមរង្គសាលបានរកចំណូលនិងបានហ្វឹកហាត់ដំណាលគ្នាជាជាងសំងំហាត់ក្នុងបន្ទប់ម្នាក់ឯង? ហើយយកពេលផ្សេងឈប់ពីហាងភីហ្សាទៅរៀនបន្តថ្នាក់បរិញ្ញាផង?»

«បៀរហ្គាឌិនឬបារនៅពេលយប់ ខ្ញុំធ្លាប់ទាំងអស់! ប៉ុន្តែនិយាយដោយស្មោះ ការច្រៀងនៅទីនោះមិនមែនជាការហ្វឹកហាត់ទេ ប៉ុន្តែអាចធ្វើឱ្យយើងខូចបំពង់កផង ប្រសិនបើត្រូវថៅកែតម្រូវឱ្យយើងញ៉ាំស្រាជាមួយភ្ញៀវ ឬមួយក៏តម្រូវយើងច្រៀងលើសពីអ្វីដែលយើងគួរធ្វើ! មានម្តងខ្ញុំធ្លាប់ត្រូវបានគេបណ្តេញដោយសារតែមិនព្រមចុះញ៉ាំស្រាជាមួយនឹងភ្ញៀវស្រីៗដែលមកហូបស្រាព្រោះខូចចិត្ត!»

អង្គអាចយល់បាន អំពីសភាពដែលវណ្ណកំពុងសំដៅដល់។ មនុស្សមានគ្រប់ប្រភេទនៅក្នុងសង្គមបច្ចុប្បន្ន ហើយអ្នកសិល្បៈត្រូវបានឱ្យតម្លៃទាប អាស្រ័យលើការប្រព្រឹត្តរបស់អ្នកសិល្បៈខ្លួនឯងខ្លះ និងចរិតភ្ញៀវមួយចំនួនដែលខ្សោយសីលធម៌ខ្វះការគោរពមនុស្សដូចគ្នា។

«ខ្ញុំជឿ! ដូច្នេះហើយយើងត្រូវតែតស៊ូ!» នាងបន្ថែម។

«ខ្ញុំបានតស៊ូរួចហើយអង្គ! ច្រើនដងហើយ! ខ្ញុំចេញពីហាងមួយច្រៀងហាងមួយទៀត! ខ្ញុំមានគោលដៅច្បាស់លាស់ គឺហាត់ពត់ សមសំឡេង ទោះលុយចំណូលតិចប៉ុណ្ណោ និងទោះគេមើលមកយើងដោយក្រសែភ្នែកបែបណា! ប៉ុន្តែ ខ្ញុំចុងក្រោយត្រូវចុះចាញ់»

គេឈប់ស្ងៀម នាងសួរៈ

«ដោយសារយ៉ាងម៉េច?»

«ខ្ញុំមិនចង់និយាយទៀតទេ! អូខេ វាជារឿងដែលធ្វើមានការអៀនខ្មាសសូម្បីរំឮកមកប្រាប់អង្គ!»

«អូខេអ៊ីចឹងយើងផ្តោតលើបច្ចុប្បន្នវិញ!»

ក្រោយមកនាងបានដឹងទៀតថាសក្តាវណ្ណធ្លាប់ត្រូវបានស្ត្រីមេម៉ាយអ្នកមានប្រាក់ប៉ុន្តែគ្មានសុភមង្គលក្នុងគ្រួសារនិងខ្សោយសីលធម៌ពួកគេសំចតជីវិតពេលរាត្រីនៅតាមបៀរហ្គាដិនស្វែងរកកំលោះសង្ហាដូចជាគេ មកកំដរជាគូគាប់ទ្រនាប់ចិត្តប៉ុន្តែសក្តាវណ្ណមិនអាចធ្វើបាន ជាហេតុធ្វើឱ្យមានការថ្នាំងថ្នាក់។

ការចេះមានគោលការណ៍ច្បាស់លាស់ គោរពនិងឱ្យតម្លៃខ្លួនឯងនេះ គឺជាចំណុចថ្មីបន្ថែមដែលញ៉ាំងឱ្យអង្គ កាន់តែពេញចិត្តឡើងទៀតចំពោះសក្តាវណ្ណ រំពៃរកមធ្យោបាយបែបណាដើម្បីឱ្យជួយគេបាន។

ទីបំផុត មិនបានប៉ុន្មាននាងទាក់ទងទៅលោកពិស្តា។

«អូបង ខ្ញុំភ្លេចរឿងមួយដែលចង់ជម្រាបបងនៅថ្ងៃនោះ! ខ្ញុំបានឃើញការប្រឡងនៅខាងក្រោមដែលមានបេក្ខជនច្រើនគួរសមដែរ! គឺពេលសាកសំឡេងផ្ទាល់ ខ្ញុំគិតថាបងពិស្តាជាអ្នកសិល្បៈម្នាក់ដែលមានបទពិសោធខ្ពស់ ខ្ញុំយល់ថាបើសិនជាបងបាននៅខាងក្រោម ព្រឹកនោះបងប្រាកដជារើសមនុស្សម្នាក់ទៅសាកសំឡេងនៅក្នុងបន្ទប់ស្ទូឌីយោព្រោះសំឡេងគេនិងអីនរបស់គេមានអ្វីមួយប្រាប់មកថា ពិបាករក ស្តាប់ទៅងាយស្រួលដកដង្ហើម ពីរោះ លួងលោម មិនតឹងតែង»

«អ្នកណា? ចាំឈ្មោះបានអត់លក្ខិណា?»

លោកពិស្តាសួរមកវិញហាក់ចាប់អារម្មណ៍នាងមានឱកាសនិយាយបន្ថែមភ្លាមៈ

«ខ្ញុំអត់ចាំទេបង! ប៉ុន្តែ អូបង! គឺម្នាក់នៅប្រលងក្រោយគេបង្អស់ ជាបេក្ខជនដែលគេបិទបញ្ចប់នៅព្រឹកនោះ!»

«អូ! អូខេចាំបងឆែក! អរគុណលក្ខិណាច្រើន!»